SaverAsia

# ការណែនាំសម្រាប់អ្នកប្រើប្រាស់

ខែកញ្ញា ឆ្នាំ២០១៨

# ឯកសារណែនាំអំពី

SaverAsia

## សន្សំពេលវេលា សន្សំប្រាក់ សន្សំដើម្បីអនាគតរបស់អ្នក

### តើ SaverAsia ជាអ្វី?

SaverAsia គឺជាគេហទំព័រដែលអ្នកអាចប្រើប្រាស់បានដោយឥតគិតថ្លៃ នឹងជួយអ្នកនៅក្នុងប្រទេសថ្មីដែលអ្នកទើបទៅដល់ដើម្បី៖

១. ប្រៀបធៀបការចំណាយ និងសេវានានាសម្រាប់ការផ្ញើប្រាក់ទៅផ្ទះ

២. ស្វែងរកសេវាហិរញ្ញវត្ថុដែលអាចជួយអ្នកបាននៅគ្រប់ទីកន្លែងដែលអ្នកកំពុងរស់នៅ

៣. តភ្ជាប់ទៅកាន់អង្គការ និងអ្នកផ្តល់សេវាគាំទ្រនានាដែលស្ថិតនៅកៀកជាមួយអ្នក

បច្ចុប្បន្ន SaverAsia រួមមានព័ត៌មានសម្រាប់កម្មករនិយោជិតកម្ពុជាដែលកំពុងរស់នៅក្នុងប្រទេសម៉ាឡេស៊ី និងប្រទេសថៃ។ គេហទំព័រនេះ នឹងត្រូវពង្រីកដើម្បីដាក់បញ្ចូលព័ត៌មានបង្ហាញផ្សេងៗសម្រាប់ប្រជាជនភូមាដែលកំពុងធ្វើការនៅក្នុងបណ្តាប្រទេសជនទៃជាច្រើនទៀត។ គេហទំព័រនេះ អាចជួយអ្នក និងជំរុញលើកទឹកចិត្តអ្នកនៅគ្រប់ទីកន្លែងដែលអ្នកកំពុងរស់នៅ។

# ការប្រៀបធៀបការផ្ទេរប្រាក់



**តើអ្នកកំពុងមានផែនការផ្ញើប្រាក់ទៅផ្ទះមែនទេ?**
**តើអ្នកកំពុងចង់ដឹងថា តើគួរផ្ញើប្រាក់ប្រកបដោយភាពឆ្លាតវៃដោយរបៀបណា?**
**ប្រសិនបើដូច្នេះនោះ SaverAsia គឺជាជម្រើសមួយសម្រាប់អ្នក**

ប្រៀបធៀបសេវាផ្ទេរប្រាក់ (បញ្ជូនសាច់ប្រាក់) ដើម្បីស្វែងរកតម្លៃ និងផលិតផលល្អបំផុតនៅពេលអ្នកផ្ញើប្រាក់ទៅផ្ទះ។

តើហេតុអ្វីបានជាគួរប្រៀបធៀបសេវាផ្ទេរប្រាក់នៅលើ SaverAsia?

- សេវារបស់ SaverAsia គឺឥតគិតថ្លៃ អ្នកពុំត្រូវបង់ការចំណាយអ្វីទាំងអស់
- សេវានេះ ជួយសន្សំពេលវេលារបស់អ្នកក្នុងការប្រៀបធៀបការចំណាយលើថ្លៃសេវា និងអត្រាប្តូរប្រាក់បានយ៉ាងឆាប់រហ័ស និងងាយស្រួល
- អ្នកស្វែងរកអត្រាថ្លៃសេវាដែលល្អជាងគេបំផុត

មិនថាអ្នកកំពុងផ្ញើប្រាក់ទៅកាន់គណនីធនាគារនៅក្រុងភ្នំពេញ ឬទៅកាន់កាបូបប្រាក់ទូរសព្ទដៃរបស់មនុស្សជាទីស្រឡាញ់របស់អ្នកនៅក្នុងតំបន់ដាច់ស្រយាលយ៉ាងណាក្តី អ្នកអាចសិក្សាបន្ថែមអំពីសេវាផ្សេងៗជាច្រើនដែលមានសម្រាប់អ្នកតាមរយៈការប្រើប្រាស់ SaverAsia។ សេវាដែលមានសម្រាប់អ្នក រួមមានដូចជា៖

- សាច់ប្រាក់ទៅសាច់ប្រាក់ 
- សាច់ប្រាក់ទៅកាន់គណនីធនាគារ 
- គណនីធនាគារទៅកាន់គណនីធនាគារ 
- គណនីធនាគារទៅកាន់កាបូបសាច់ប្រាក់ទូរសព្ទដៃ 
- បណ្ណឥណពន្ធទៅកាន់គណនីធនាគារ 
- សាច់ប្រាក់បញ្ជូនទៅដល់ផ្ទះ 

១. “ជ្រើសរើសប្រទេសដែលអ្នកបញ្ជូនប្រាក់ចេញ និងបញ្ជូនប្រាក់ទៅកាន់”




២. “ជ្រើសរើសពាក្យប្រៀបធៀបដើម្បីទទួលបានសេវាល្អបំផុត” នៅលើទំព័រនេះ អ្នកមានជម្រើសពីរសម្រាប់ប្រៀបធៀបការចំណាយ៖




- **ប្រៀបធៀបអត្រាផ្សាយផ្ទាល់៖** ថ្លៃចំណាយដែលត្រូវបានបង្ហាញក្នុងតារាងនេះគួរតែជាការចំណាយ**ផ្សាយផ្ទាល់**សម្រាប់សេវាបញ្ជូនសាច់ប្រាក់នាពេល**ឥឡូវនេះ**

- **ប្រៀបធៀបគ្រប់ជម្រើសទាំងអស់៖** ទិន្នន័យនៅលើតារាងនេះ ត្រូវបានប្រមូលរៀងរាល់ ១-៣ ខែម្តង។ ទិន្នន័យនេះ រួមមានសេវាផ្សេងៗទៀត ក្រៅពីសេវាដែលមានបង្ហាញនៅលើតារាង “អត្រាផ្សាយផ្ទាល់” រួមទាំងព័ត៌មានស្តីពីអ្នកផ្តល់សេវាផ្ទេរប្រាក់ដែលពុំបានផ្តល់អត្រាផ្សាយផ្ទាល់។




| Operator | Type | Method of Transfer | Fee (THB) | Total Cost (THB) | Total Cost (%) | Amount Received | Speed of Transfer | Network Coverage |
|---|---|---|---|---|---|---|---|---|
| Xpress Money | | | 1180.00 | 68.90 | 13.78 | KHR 573626.27 | 12 | Low |
| Western Union | | | 600.00 | 47.90 | 9.58 | USD 162.00 | 1 | High |
| UOB Bank | | | 1150.00 | 34.15 | 6.83 | USD 154.72 | 12 | Low |
| TMB Bank | | | 1200.00 | 35.85 | 7.17 | USD 152.64 | 2 | Low |
| Siam Commercial Bank | | | 1200.00 | 35.85 | 7.17 | USD 152.64 | 12 | Low |
| MoneyGram | | | 800.00 | 46.35 | 9.27 | USD 634706.80 | 1 | High |
| Krungthai Bank | | | 1200.00 | 35.85 | 7.17 | USD 152.64 | 3-5 | Low |
| Krungsri Bank | | | 1300.00 | 40.25 | 8.05 | USD 148.99 | 3-5 | Low |
| Kasikorn Bank | | | 1200.00 | 36.00 | 7.20 | USD 152.64 | 3-5 | Low |
| Bangkok Bank | | | 1150.00 | 34.30 | 6.86 | USD 154.72 | 3-5 | Low |

# ការសន្សំប្រាក់

**តើអ្នកកំពុងគិតចង់៖**

- **បើកគណនីធនាគារ**
- **ទិញធានារ៉ាប់រង?**
- **តាមដានការចំណាយ និងការសន្សំប្រាក់ប្រចាំខែរបស់អ្នក?**

**ប្រសិនបើដូច្នេះនោះ SaverAsia គឺជជម្រើសមួយសម្រាប់អ្នក**

SaverAsia អាចជួយអ្នកឱ្យស្វែងរក និងរៀនសូត្របន្ថែមអំពីសេវាហិរញ្ញវត្ថុល្អៗ នៅគ្រប់ទីកន្លែងដែលអ្នកកំពុងរស់នៅ។ កញ្ចប់សន្សំប្រាក់អាចជួយអ្នកឱ្យសិក្សាបន្ថែមអំពីសេវាហិរញ្ញវត្ថុផ្សេងៗដែលអាចមានសម្រាប់អ្នកនៅក្នុងប្រទេសថ្មីដែលអ្នកទើបមកដល់។ អ្នកអាចសិក្សាអំពីរបៀបបើកគណនីធនាគារ ឬស្វែងរកអំពីផលិតផលធានារ៉ាប់រងផ្សេងៗដែលមាន។ SaverAsia ក៏ជួយភ្ជាប់ទំនាក់ទំនងអ្នកទៅកាន់វគ្គសិក្សាអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុដែលអាចមានសម្រាប់អ្នក នៅក្នុងប្រទេសថ្មីដែលអ្នកទើបមកដល់ផងដែរ។




អ្នកអាចប្រើប្រាស់ម៉ាស៊ីនគិតលេខកញ្ចប់ថវិកា SaverAsia ដើម្បីតាមដានការចំណាយរបស់អ្នក និងកំណត់គោលដៅសន្សំប្រាក់ដោយខ្លួនអ្នកផ្ទាល់។

# ការគាំទ្រក្នុងមូលដ្ឋាន

**តើអ្នកកំពុងស្វែងរកព័ត៌មានដើម្បីសិក្សាបន្ថែមអំពី៖**

- **សេវាគាំទ្រក្នុងមូលដ្ឋាននៅក្នុងប្រទេសថ្មីដែលអ្នកបានមកដល់**
- **ព័ត៌មានអំពីចំណាកស្រុកដោយសុវត្ថិភាពទៅកាន់ប្រទេសថ្មី**
- **ឬព្យាយាមសិក្សាបន្ថែមទៀតអំពីអ្វីដែលអាចមាន និងផ្តល់ជូននៅក្នុងប្រទេសថ្មីដែលអ្នកទើបមកដល់?**

**ប្រសិនបើដូច្នេះនោះ SaverAsia គឺសម្រាប់អ្នក**

SaverAsia ផ្តល់ព័ត៌មានដើម្បីជួយអ្នកមុនពេលចេញដំណើរ និងពេលដែលអ្នកកំពុងស្ថិតនៅក្នុងប្រទេសថ្មីដែលទើបមកដល់។ មិនថាអ្នកធ្វើការ និងរស់នៅទីណាក្តី SaverAsia នឹងអាចផ្តល់ការគាំទ្រនៅក្នុងមូលដ្ឋានផ្ទាល់ជូនដល់អ្នក។ សេវាគាំទ្រក្នុងមូលដ្ឋានរបស់ SaverAsia អាចជួយអ្នកឱ្យយល់ដឹងព័ត៌មាន ចាប់តាំងពីបញ្ហាសុខភាព ទិដ្ឋាការ និងការអប់រំ រហូតដល់ព័ត៌មានស្តីពីការធ្វើដំណើរការកម្សាន្តសប្បាយ និងកីឡា។




Australian Aid

Canada

dma developing markets associates

ILO 100 1919-2019 SOCIAL JUSTICE DECENT WORK

SaverAsia ត្រូវអភិវឌ្ឍឡើងរួមគ្នាដោយ Developing Markets Associates (DMA) និង Republisys។

តាមរយៈកម្មវិធី TRIANGLE in ASEAN  អង្គការ ILO កំពុងផ្តល់ការគាំទ្រមួយផ្នែកដើម្បីបង្កើត និងថែរក្សាគេហទំព័រនេះ។ TRIANGLE in ASEAN បានទទួលការគាំទ្រពីក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី និងក្រសួងពាណិជ្ជកម្ម និងកិច្ចការពិភពលោករបស់ប្រទេសកាណាដា។